**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ ៤០០ សាក.១៧/អអក

ភ្នំពេញ, ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
## ស្តីពីការពិគ្រោះយោបល់សាធារណៈក្នុងការកែសម្រួលអាជ្ញាបណ្ណរបស់លោកស្រី អ៊ាម ស្រេង សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម

អាជ្ញាធរអគ្គិសនីកម្ពុជា មានកិត្តិយសសូមជម្រាបជូនសាធារណជននៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជាបានចេញអាជ្ញាបណ្ណលេខ ០៦០ អ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៣ ឲ្យលោកស្រី អ៊ាម ស្រេង សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ក្នុងអាណត្តិមុនគឺ ៧ឆ្នាំ ។ ក្នុងអាណត្តិនេះលោកស្រី អ៊ាម ស្រេង បានធ្វើការសាងសង់ និងកែលម្អមធ្យោបាយធ្វើសេវាកម្មអគ្គិសនីស្របតាមស្តង់ដាបច្ចេកទេសអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដោយយល់ឃើញថា លោកស្រី អ៊ាម ស្រេង មានឆន្ទៈក្នុងការកែលម្អ និងបង្កើនប្រសិទ្ធភាពអាជីវកម្មរបស់ខ្លួនបន្ថែមទៀត ដូច្នេះ អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណឲ្យលោកស្រី អ៊ាម ស្រេង ដោយបង្កើនអាណត្តិអាជ្ញាបណ្ណពី ៧(ប្រាំពីរ)ឆ្នាំ ទៅ ១២(ដប់ពីរ)ឆ្នាំ ដូចមានជូនភ្ជាប់មកជាមួយនេះ ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការកែសម្រួលអាជ្ញាបណ្ណ អាជ្ញាធរមូលដ្ឋាន ស្ថាប័ននានាដែលពាក់ព័ន្ធ និងសាធារណជនមានសិទ្ធិពិនិត្យផ្តល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា លើខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណ ដែលគ្រោងនឹងចេញនេះ ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណនៅ..... ...................... ........................................................................................................សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះ សូមសាធារណជននៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្តល់យោបល់លើខ្លឹមសារនៃការចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណឲ្យលោកស្រី អ៊ាម ស្រេង អាចអញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៧ ។ អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា **"អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណា ដែលមានបង្ហាញនូវហេតុផលយ៉ាងច្បាស់លាស់ប៉ុណ្ណោះ"** ។ល។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ទី នរិន្ទ**

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
**ទូរស័ព្ទ** : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ **ទូរសារ** : ០២៣ ២១៤ ១៤៤, **អ៊ីម៉ែល** : admin@eac.gov.kh ; Website : www.eac.gov.kh

**សេចក្ដីព្រាង**

# អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA

## ច្បាប់ស្ដីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
ELECTRICITY LAW OF THE KINGDOM OF CAMBODIA

## សេចក្ដីសម្រេចកែសម្រួលលើកទី៦
## លើឯកសារអាជ្ញាបណ្ណលេខ ០៦០ ឯអ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៣ សម្រាប់លោកស្រី អ៊ាម ស្រេង ធ្វើសេវាកម្មអគ្គិសនី នៅឃុំមេសរជ្រៃ និងឃុំសុភាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម

## សម្រាប់ការបង្កើនអាណត្តិអាជ្ញាបណ្ណ

**DECISION ON THE SIXTH REVISION**

OF THE LICENSE DOCUMENT No. 060 LD DATED NOVEMBER 20, 2003 FOR MRS. EAM SRENG FOR PROVIDING ELECTRIC POWER SERVICE AT KHUM MESORCHREY AND KHUM SOPHEAS, STUNG TRANG DISTRICT, KAMPONG CHAM PROVINCE

**FOR INCREASING TERM OF LICENSE**

ថ្ងៃទី... ខែ...... ឆ្នាំ២០១៧

... ... ..., 2017

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA
លេខ ៖ -១៧-អអក

# សេចក្តីសម្រេចកែសម្រួលលើកទី៦ លើឯកសារអាជ្ញាបណ្ណលេខ ០៦០ ឯអ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៣ សម្រាប់លោកស្រី អ៊ាម ស្រេង

# DECISION ON THE SIXTH REVISION OF THE LICENSE DOCUMENT No. 060 LD DATED NOVEMBER 20, 2003 FOR MRS. EAM SRENG

## អាជ្ញាធរអគ្គិសនីកម្ពុជា
## ELECTRICITY AUTHORITY OF CAMBODIA

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

- In exercise of the powers conferred by Article 7 and 35 of the Electricity Law promulgated by the Royal Decree NS/RKM/0201/03, dated February 02, 2001.

-យោងឯកសារអាជ្ញាបណ្ណលេខ ០៦០ ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញឲ្យលោកស្រី អ៊ាម ស្រេង នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៣

- In accordance with License Document No. 060 LD issued by Electricity Authority of Cambodia on November 20, 2003 to Mrs. Eam Sreng.

-យោងពាក្យស្នើសុំបង្កើនអាណត្តិអាជ្ញាបណ្ណរបស់លោកស្រី អ៊ាម ស្រេង ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧

- In accordance with the application of Mrs. Eam Sreng for increasing term of license, dated April 24, 2017.

-យោងកំណត់បង្ហាញបង្កើនអាណត្តិអាជ្ញាបណ្ណរបស់លេខាធិការដ្ឋានលេខ ០៣០-១៧-លជ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧

- In accordance with the request for increasing term of Secretariat Office N° 030-17 dated July 06, 2017.

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី... ខែ..... ឆ្នាំ២០១៧ ដល់ថ្ងៃទី... ខែ..... ឆ្នាំ២០១៧

- In accordance with the consultation with concerned parties and public, made from........., 2017 to......, 2017.

-យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី... នៅថ្ងៃទី..... ខែ...... ឆ្នាំ២០១៧

- In accordance with the decision of Electricity Authority of Cambodia's Session No......., dated........., 2017.

# **សម្រេច**
# DECIDES

| | |
|---|---|
| **ប្រការ១**<br>ដោយលោកស្រី អ៊ាម ស្រេង (បន្ទាប់ពីនេះ ហៅថា "**អ្នកកាន់អាជ្ញាបណ្ណ**") បានសាងសង់ និងកែលម្អមធ្យោបាយធ្វើសេវាកម្មអគ្គិសនីរបស់ខ្លួនស្របតាមស្តង់ដាបច្ចេកទេសអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចកែសម្រួលឯកសារអាជ្ញាបណ្ណលេខ ០៦០ ឯអ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៣ ដែលបានផ្តល់ជូនអ្នកកាន់អាជ្ញាបណ្ណ ដោយបង្កើនអាណត្តិអាជ្ញាបណ្ណពី ៧(ប្រាំពីរ) ឆ្នាំ ទៅ ១២(ដប់ពីរ)ឆ្នាំ ។ អាណត្តិថ្មីរបស់អាជ្ញាបណ្ណនេះមានរយៈពេល ១២ (ដប់ពីរ)ឆ្នាំ គិតចាប់ពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១២ និងអាចស្នើសុំបន្តទៀត ឬស្នើសុំកែសម្រួល លើកលែងតែត្រូវដកហូតដោយអនុលោមតាមលក្ខខណ្ឌនៃអាជ្ញាបណ្ណនេះ ។ | **Article 1**<br>As Mrs. Eam Sreng (herein after referred to as "**Licensee**") has improved its facilities and constructed new facilities in accordance with Electric Power Technical Standards of the Kingdom of Cambodia, EAC decides to revise license document No. 060 LD dated November 20, 2003 granted to licensee by increasing term of license from 7 (Seven) years to 12 (Twelve) years . The new term of the license shall be 12 (Twelve) years from November 20, 2012 and may be renewed for further periods unless revoked earlier in accordance with the conditions of license. |
| **ប្រការ២**<br>ខ្លឹមសារ និងលក្ខខណ្ឌដទៃទៀតនៃឯកសារអាជ្ញាបណ្ណលេខ ០៦០ ឯអ ត្រូវស្ថិតនៅជាធរមានដដែល ។ | **Article2**<br>The other contents and conditions of the license document No. 060 LD shall remain in force. |
| **ប្រការ៣**<br>សេចក្តីសម្រេចនេះ ត្រូវចាត់ទុកជាផ្នែកមួយនៃឯកសារអាជ្ញាបណ្ណលេខ ០៦០ ឯអ ។ | **Article 3**<br>This decision shall be considered as a part of the license document No. 060 LD. |
| **ប្រការ៤**<br>សេចក្តីសម្រេចនេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃបើកសម័យប្រជុំលើកទី ... តទៅ ។ | **Article 4**<br>This decision shall come into force from the date of session No. .... |
| **ប្រការ៥**<br>អ្នកកាន់អាជ្ញាបណ្ណត្រូវផ្ញើសេចក្តីសម្រេចនេះទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែងដែលឯកសារអាជ្ញាបណ្ណលេខ ០៦០ ឯអ បានតម្កល់ទុកពីមុន ដើម្បីឲ្យឯកសារអាជ្ញាបណ្ណលេខ ០៦០ ឯអ ដែលតម្កល់ទុកមានការកែសម្រួលជាថ្មី ស្របតាមសេចក្តីសម្រេចនេះ ។ | **Article 5**<br>The licensee shall send this decision to deposit additionally at the places, where the license document No. 060 LD has been deposited in order that the deposited license document No. 060 LD is in conformity with this decision. |

ភ្នំពេញ, ថ្ងៃទី... ខែ...... ឆ្នាំ២០១៧

Phnom Penh,........., 2017

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

CHAIRMAN OF ELECTRICITY AUTHORITY OF CAMBODIA